ប្រការ ៤ : ព្រឹទ្ធបុរសមហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបង្កើតក្រុមប្រឹក្សាភិបាលមួយ ដើម្បីទទួលខុសត្រូវលើផ្នែកសិក្សា រដ្ឋបាលនិងហិរញ្ញកិច្ច និងត្រូវធ្វើបទបញ្ជាផ្សេងៗ ដើម្បីគ្រប់គ្រងថ្នាក់នេះអោយមានគុណភាពល្អ ។

ប្រការ ៥ : តំលៃនៃការសិក្សា ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃមហាវិទ្យាល័យ ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ នឹងមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៨ : សេចក្តីសំរេចនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៨

## សេចក្តីសំរេចលេខ ២៤ សសរ

## ស្តីពីការប្តូរឈ្មោះមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ទៅជា វិទ្យាស្ថានជាតិគ្រប់គ្រង និង ការបើកថ្នាក់ បរិញ្ញាបត្រ សិក្សាតាមរូបភាពបង់ថ្លៃ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ និងយុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស

-តាមសំណើរបស់ ក្រសួងអប់រំ និង យុវជន និងកីឡា

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយ មហាវិទ្យាល័យពាណិជ្ជសាស្ត្រ ប្តូរឈ្មោះទៅជាវិទ្យាស្ថានជាតិគ្រប់គ្រង អក្សរកាត់ ( វ ជ គ ) និងអនុញ្ញាតអោយបើកថ្នាក់ បរិញ្ញាបត្រ សិក្សាតាមរូបភាពបង់ថ្លៃ ចាប់ផ្តើមពីឆ្នាំសិក្សា ១៩៩៧-៩៨ នេះតទៅ ។

ប្រការ ២ : លក្ខខណ្ឌចូលសិក្សា :

-ជាជនគ្រប់រូប

-មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ( BAC II ) ឬ សញ្ញា[illegible]ស្មើ សញ្ញាបត្រមធ្យមសិក្សាបច្ចេកទេស ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម ហិរញ្ញវត្ថុ ធនាគារ ។

-ប្រលងចេញជាប់មុនចូលសិក្សា

ប្រការ ៣ : របៀបសិក្សា

-ថ្នាក់ បរិញ្ញាប័ត្រសិក្សាបង់ថ្លៃ អនុវត្តកម្មវិធីសិក្សារយៈពេល៤ឆ្នាំ ត្រូវជា១៦២ ក្រេឌីតដូចគ្នានឹងថ្នាក់បរិញ្ញាបត្រនីតិសាមញ្ញដែរ ។

-ប្រព័ន្ធសិក្សាបង់ថ្លៃ និងប្រព័ន្ធសិក្សានីតិសាមញ្ញមិនអាចឆ្លងគ្នាទៅវិញទៅមកបានទេ ។

-ចុងឆមាសនៃឆ្នាំសិក្សានីមួយៗ និស្សិតត្រូវប្រលងបញ្ចប់គ្រប់មុខវិជ្ជាក្នុងកម្មវិធីប្រកបដោយជោគជ័យ ។

ក្នុងករណីពិន្ទុផលមិនបានតាមការកំណត់ ឬ អវត្តមាន ៣/៥ នៃម៉ោងសិក្សាតាមមុខវិជ្ជា ត្រូវត្រួតថ្នាក់ ។

-ការជ្រើសរើសឲ្យធ្វើបទបញ្ញាមួយវិទ្យាស្ថានត្រូវស្របទៅតាមឈ្មោះចេញពីបញ្ជីសិក្សា ។

-ស្រុងរាល់ចុងឆ្នាំទី៤ និស្សិតត្រូវការពារតំរោងសារណារបស់ខ្លួនដោយ ជោគជ័យទើបទទួលបានបរិញ្ញាបត្រ ។

-បរិញ្ញាបត្រសិក្សាបង់ថ្លៃ មានតំលៃស្មើគ្នានឹងបរិញ្ញាបត្រនីតិសាមញ្ញ តែសន្លឹកសញ្ញាប័ត្រមានពណ៌ខុសគ្នា ។

-វិទ្យាស្ថានជាតិគ្រប់គ្រង ជាអ្នកចេញបរិញ្ញាបត្រ ដែលមានការទទួលស្គាល់ពី ក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ៤ : តំលៃសិក្សាត្រូវបានកំណត់ដោយ ក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន ។

ប្រការ ៥ : នាយកវិទ្យាស្ថានជាតិគ្រប់គ្រង ទទួលខុសត្រូវរួមលើផ្នែករដ្ឋបាល សិក្សា ហិរញ្ញវត្ថុ និង ត្រូវធ្វើបទបញ្ញាផ្សេងៗ ដើម្បីគ្រប់គ្រងថ្នាក់នេះ អោយមានគុណភាព និងមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និង វិទ្យាស្ថានជាតិគ្រប់គ្រង ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៨ ៖ សេចក្ដីសម្រេចនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

## ៣-លិខិតបញ្ជា

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩

### លិខិតបញ្ជាលេខ ២៣ ល.ប

### ស្ដីពីវិធានការទប់ស្កាត់អំពើគេចពន្ធ

### នៅតាមច្រកចេញ-ចូលព្រំដែន

***

**ជូនចំពោះ**

-ឯកឧត្ដម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-ឯកឧត្ដម សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

-ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ឯកឧត្ដម នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ

-ឯកឧត្ដម អភិបាលខេត្តបន្ទាយមានជ័យ បាត់ដំបង ស្វាយរៀង តាកែវ កណ្ដាល កោះកុង កំពត កំពង់ចាម ព្រៃវែង ក្រចេះ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ពោធិ៍សាត់ សៀមរាប ព្រះវិហារ និងក្រុងព្រះសីហនុ

-ឯកឧត្ដម ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងប៉ៃលិន និង ក្រុងកែប

-លោកមេបញ្ជាការយោធភូមិភាគទី១ ទី២ ទី៣ ទី៤ និងទី៥

-លោកប្រធានទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិ-តំបន់ព្រំដែន និង ទេសភាពគី

ក្នុងរយៈពេល ៥ ខែ ដើមឆ្នាំ ១៩៩៩ កន្លងទៅនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ៖ ចំណូលប្រាក់ពន្ធគយដែលប្រមូលបាន នៅតាមមាត់ច្រកនាំចេញ-នាំចូលទំនិញនៅទូទាំងប្រទេស មានការថយចុះយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងគំរោងចំណូលប្រាក់ពន្ធគយប្រចាំខែ ក្នុងឆ្នាំ ១៩៩៩ នេះ ។ ការថយចុះនូវចំណូលប្រាក់ពន្ធ កណ្ដាលមកពីមូលហេតុសំខាន់ៗមួយចំនួន ដូចតទៅ ៖

១-សកម្មភាពនាំចេញ - នាំចូលទំនិញនៅតាមមាត់ច្រកសំខាន់ៗ ជាអាទិ៍ ច្រកនាំចេញ-នាំចូល តាមព្រំដែននៃខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ផែទំនប់លោកក្រុងព្រះសីហនុ ខេត្តស្វាយរៀង តាកែវ កណ្ដាល ជាពិសេសច្រកប៉ៃលិន បាននិងកំពុងប្រព្រឹត្តទៅជាធម្មតា ពុំមានការថយចុះទេ ។ ប៉ុន្តែសកម្មភាពគេចពន្ធបានកើនឡើងយ៉ាងគ្រឹកគគ្រេងបំផុត ដែលសម្ដែងតែមានការចូលរួមការពារទំនិញពីសំណាក់ជនខិលខូចមួយចំនួន ។ ដោយឡែកសកម្មភាពគេចពន្ធតាមច្រករបៀងខុសច្បាប់បានកើតឡើងយ៉ាងអនាធិបតេយ្យរាប់សិប